ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែឧទ្យានជាតិបទុមសាគរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ ._**

ត្រូវបានកែប្រែឧទ្យានជាតិបទុមសាគរ ពីផ្ទៃដីទំហំ១៧១ ២៥០(មួយសែនប្រាំពីរម៉ឺនមួយពាន់ពីររយហាសិប)ហិកតា ដែលមានចែងក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ មកផ្ទៃដីទំហំ១៤៣ ៨៩៥(មួយសែនបួនម៉ឺនបីពាន់ប្រាំបីរយកៅសិបប្រាំ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា( តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 )ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា២ ._**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សា ការពារសោភណភាពធម្មជាតិ និងទេសភាព ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ សម្រាប់វិទ្យាសាស្ត្រ ការអប់រំ ការសិក្សាស្រាវជ្រាវ និងការកម្សាន្ត
- លើកកម្ពស់តួនាទី សក្តានុពល និងកិត្យានុភាពនៃប្រព័ន្ធអេកូឡូស៊ី ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ជំរុញនិងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ ._**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ឧទ្យានជាតិបទុមសាគរ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តកោះកុង ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ ._**

**មាត្រា៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣**

**ផែនទីឧទ្យានជាតិបនុមសាគរ ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង**






**សញ្ញាសម្គាល់**

- ចំណុចនិយាមកា
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:200,000

0 2 4 8 km

Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984

**ឧទ្យានជាតិបនុមសាគរ**

មានផ្ទៃដីទំហំ ១៤៣ ៨៥៥ហិកតា

**ប្រភពទិន្នន័យ**

ព្រំប្រទល់ ... : ក្រសួងបរិស្ថាន

ព្រំប្រទល់ ... : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០២១)

ផ្កាយរណប : Google Earth

រៀបចំដោយ : នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រនៃក្រសួងបរិស្ថាន

**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៧៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣**

**ចំណុចនិយាមការនៃផែនទីឧទ្យានជាតិបន្ទុមសាគរ**

| ID | X | Y |
|---|---|---|
| 1 | 301581 | 1206324 |
| 2 | 299592 | 1206323 |
| 3 | 299605 | 1216313 |
| 4 | 301591 | 1216322 |
| 5 | 301591 | 1218324 |
| 6 | 301591 | 1222322 |
| 7 | 299592 | 1222322 |
| 8 | 299592 | 1224322 |
| 9 | 301591 | 1226323 |
| 10 | 301590 | 1232321 |
| 11 | 299592 | 1234323 |
| 12 | 299594 | 1238322 |
| 13 | 291799 | 1238319 |
| 14 | 289873 | 1241414 |
| 15 | 288600 | 1240927 |
| 16 | 287509 | 1240460 |
| 17 | 286740 | 1241359 |
| 18 | 287878 | 1242538 |
| 19 | 289283 | 1242914 |
| 20 | 288816 | 1245119 |
| 21 | 289998 | 1246322 |
| 22 | 289316 | 1248174 |
| 23 | 291008 | 1248404 |
| 24 | 291932 | 1249890 |
| 25 | 294356 | 1250501 |
| 26 | 296716 | 1251395 |
| 27 | 297116 | 1252862 |
| 28 | 295499 | 1255227 |
| 29 | 292935 | 1254957 |
| 30 | 291645 | 1256780 |
| 31 | 291325 | 1259039 |
| 32 | 291329 | 1261078 |
| 33 | 293077 | 1261935 |
| 34 | 294652 | 1262960 |
| 35 | 296896 | 1263343 |
| 36 | 298601 | 1264483 |
| 37 | 299760 | 1264138 |
| 38 | 302072 | 1262248 |
| 39 | 304098 | 1260388 |

| ID | X | Y |
|---|---|---|
| 40 | 306649 | 1258918 |
| 41 | 309620 | 1258519 |
| 42 | 311432 | 1256602 |
| 43 | 312970 | 1254055 |
| 44 | 315799 | 1252788 |
| 45 | 318493 | 1247626 |
| 46 | 321416 | 1242397 |
| 47 | 322668 | 1239817 |
| 48 | 323738 | 1237407 |
| 49 | 326615 | 1236780 |
| 50 | 329255 | 1236364 |
| 51 | 330730 | 1235403 |
| 52 | 331960 | 1233816 |
| 53 | 334252 | 1233844 |
| 54 | 333021 | 1231004 |
| 55 | 329619 | 1227440 |
| 56 | 332793 | 1227847 |
| 57 | 330540 | 1223302 |
| 58 | 329397 | 1219589 |
| 59 | 327995 | 1215884 |
| 60 | 326478 | 1212255 |
| 61 | 327410 | 1208515 |
| 62 | 327934 | 1204763 |
| 63 | 325511 | 1203774 |
| 64 | 323334 | 1202692 |
| 65 | 323341 | 1202936 |
| 66 | 323532 | 1204251 |
| 67 | 325029 | 1204704 |
| 68 | 324643 | 1205183 |
| 69 | 322829 | 1205222 |
| 70 | 323424 | 1204192 |
| 71 | 323240 | 1202936 |
| 72 | 321573 | 1203186 |
| 73 | 321581 | 1206324 |
| 74 | 317580 | 1210331 |
| 75 | 315577 | 1210331 |
| 76 | 313581 | 1212323 |
| 77 | 307581 | 1212324 |
| 78 | 305604 | 1210347 |